**មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)**

ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦

# សេចក្តីប្រកាសព័ត៌មាន

*Released July 13, 2010*

# របៀបស្ទូងដើម្បីឱ្យស្រូវបែកគុម្ពបានផលច្រើន

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់កសិករ ក្នុងការកែលំអគុណភាពជីវិតរបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គម"។

សេដាក បានធ្វើការក្នុងការណែនាំនូវគំនិតសំខាន់ៗទាក់ទងនឹងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) ទៅដល់កសិករ ដើម្បីបង្កើនទិន្នផលស្រូវ តាមរយៈការប្រើប្រាស់ធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធិភាព។ ការស្ទូងដើម្បីឱ្យស្រូវបែកគុម្ពច្រើន គឺជាវិសាស្ត្រមួយដ៏មានសារៈសំខាន់ដែលបានជម្រុញដោយអង្គការ សេដាក។ តាមបទពិសោធន៍កន្លងមកស្រូវដែលបែកគុម្ពច្រើននាំមកនូវកួរច្រើន កួរវែង គ្រាប់ច្រើន និងផលខ្ពស់។ លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការ សេដាក មានប្រសាសន៍ថា ដើម្បីឱ្យស្រូវអាចបែកគុម្ពបានច្រើន កសិករគួរតែសាកល្បងអនុវត្តតាម វិធីសាស្ត្រ ៦ ចំណុចដូចខាងក្រោមនេះ

១. កុំចាំដល់សំណាបចាស់ពេក គឺសំណាបអាយុប្រហែលពី ១០ ទៅ ១៥ ថ្ងៃក៏អាចស្ទូងបានដែរ។ សំណាបខ្ចី ពេលស្ទូងទៅវាមានពេលច្រើនសំរាប់បែកគុម្ព។

២. កុំចាំមានទឹកដក់ច្រើនក្នុងស្រែបានស្ទូង គឺនៅពេលដីសើមៗ យើងអាចស្ទូងបានហើយ។ ផ្ទុយទៅវិញ បើមានទឹកដក់ច្រើនក្នុងស្រែគេគួរបង្ហូរចេញខ្លះ ពីព្រោះទឹកច្រើនពេក នាំឱ្យសំណាបលូតវែងតាមទឹក មិនសូវបែកគុម្ព ហើយដើមស្រូវមានភាពទន់ជ្រាយ និងងាយដួលរលំ។

៣. ដកតែសំណាបថ្លោសទៅស្ទូង

៤. កុំស្ទូងច្រើនពេក យកល្អ គឺស្ទូងតែ ១ ទៅ ២ ដើមក្នុងមួយគុម្ព ឬយ៉ាងច្រើនបំផុត ៣ ដើមក្នុង ១ គុម្ព។ កាលណាយើងចាប់ច្រើនដើមពេក ក្នុង ១ គុម្ព វានាំមកនូវភាពចង្អៀតដល់ស្រូវនិមួយៗក្នុងការបែកខ្នែង ឬបែកគុម្ព។

៥. ស្ទូងដោយដោតរាក់ៗបន្តិចបានហើយ។ ការស្ទូងកប់ជ្រៅពេកនាំឱ្យស្រូវត្រូវការចំណាយពេលយូរក្នុងការកកើតឬសថ្មី និងបែកខ្នែង។

៦. ស្ទូងលៃយ៉ាងណា ឱ្យចន្លោះពីគុម្ពមួយទៅគុម្ពមួយស្មើគ្នា ដើម្បីឱ្យគុម្ពនិមួយៗមានឱកាសស្មើគ្នា ក្នុងការស្រូបយក ជីជាតិ ទឹក និងពន្លឺថ្ងៃ។

លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាកមានប្រសាសន៍បញ្ជាក់បន្ថែមថា តាមបទពិសោធន៍កន្លងមក ប្រសិនបើកសិករអនុវត្តបាន តាមចំណុចទាំង ៦ ខាងលើនេះ ស្រូវ ១ គុម្ព។ នឹងបែកបានច្រើនដើម (ច្រើនជាង ៥០ ដើម) និងនាំមក នូវផលច្រើន។ តែប្រសិនបើ កសិករមិនអាចអនុវត្តតាមចំណុចទាំងអស់បាន យ៉ាងអន់ណាស់ក៏ព្យាយាមអនុវត្តនូវចំណុចទី ៣ ទី ៤ និងទី ៥ គឺដកតែសំណាបថ្មោសទៅស្ទូង ស្ទូងចាប់តិច និងស្ទូងរាក់ៗ ក៏វាអាចនាំមកនូវផលល្អប្រសើរជាងការអនុវត្តតាមធម្មតាដែរ។

**ទំនាក់ទំនង:** សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ហ៊ឹម ខទៀត: ០១៦ ៩៧៥ ៧១៣